នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Mar-2013, 14:51
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ (ជាមួយឧបសម្ព័ន្ធ ក សម្ងាត់)**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ការលើកឡើងសម្រាប់សវនាការស្នើឡើងដោយសហព្រះរាជអាជ្ញា
## (ជាមួយឧបសម្ព័ន្ធ ក សម្ងាត់)

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
ខៀវ សំផន

ក្រុមមេធាវីការពារក្តី:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Jacques VERGES
លោកស្រី Arthur VERCKEN
លោក Anta GUISSE

## សំណើ

១- សហព្រះរាជអាជ្ញាដាក់ជូននៅក្នុង**ឧបសម្ព័ន្ធ ក** នូវកាលវិភាគដែលបានស្នើឡើង សម្រាប់ការបញ្ចប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿងនេះ[1]។ កាលវិភាគនេះ កែសម្រួលផែនការមុនៗដែលបានដាក់ដោយសហព្រះរាជអាជ្ញា ក្នុងកិច្ចប្រជុំរៀបចំសវនាការ កាលពីខែសីហា ឆ្នាំ២០១២[2] ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះ ដែលបានធ្វើឡើងនៅក្នុងសវនាការនៃសប្តាហ៍ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ មរណភាពរបស់ អៀង សារី និងការវិវឌ្ឍន៍ផ្សេងទៀតនៅក្នុងកិច្ចដំណើរនីតិវិធីតាំងពីឆ្នាំមុន។ ដោយហេតុថា កាលវិភាគនេះមានការពឹងផ្អែកទៅលើការបំបែកកិច្ចដំណើរការនីតិវិធីដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា មានបញ្ចូលទីតាំងឧក្រិដ្ឋកម្ម ស-២១ ដែលសហព្រះរាជអាជ្ញាបានដាក់ជូន គួរត្រូវបូកបន្ថែមទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១។

២- កាលវិភាគសម្រាប់សវនាការដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា នឹងត្រូវបញ្ចប់សវនាការលើភ័ស្តុតាង (រួមទាំងសាក្សីមន្ទីរស-២១) ត្រឹមដំណាច់ខែកក្កដា ឆ្នាំ២០១៣ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងនឹងត្រូវឈប់សម្រាក ហើយបន្ទាប់មកទៀតនឹងបន្តកិច្ចដំណើរការនីតិវិធី ក្នុងខែកញ្ញា ឆ្នាំ២០១៣ ដើម្បីស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពីភាគីនានា។ កាលវិភាគនេះសន្មតថា សវនាការលើសាក្សីបន្តធ្វើត្រឹមថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣។ កាលវិភាគនេះ ស្នើនូវចំនួនថ្ងៃសវនាការជាក់លាក់សម្រាប់ខែនិមួយៗ ដោយមានការគិតគូរអំពីថ្ងៃឈប់សម្រាកជាសាធារណៈ និងថ្ងៃឈប់សម្រាកដែលបានប្រកាសដោយតុលាការ។ ចំនួនថ្ងៃសវនាការដែលបានរំពឹងទុកសម្រាប់ខែនិមួយៗ បង្ហាញឡើងជាអក្សរទ្រេត បន្ទាប់ពីចំណងជើងសម្រាប់ខែនោះ នៅក្នុង **ឧបសម្ព័ន្ធ ក**[3]។

៣- កាលវិភាគសវនាការដែលបានស្នើឡើងនេះ ចាប់ផ្តើមជាមួយនឹងការបញ្ចប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ចំនួន១២រូប ដែលបានជ្រើសរើសពីមុន ដោយអង្គជំនុំជម្រះសាលាដំបូង ផ្តល់សក្ខីកម្មលើបញ្ហាផ្សេងៗនៅក្នុងដំណាក់កាលទី១ (រួមទាំងរចនាសម្ព័ន្ធយោធា បកក និងតួនាទីរបស់

---

[1] **ឧបសម្ព័ន្ធ ក** ការកំណត់ពេលសវនាការដែលបានស្នើឡើងដោយ កសព។

[2] **E218/2.1** ការកំណត់ពេលសវនាការដែលបានស្នើឡើងដោយ កសព, ១៥ សីហា ២០១២។

[3] ថ្ងៃសវនាការដែលបានស្នើឡើងសម្រាប់ខែនិមួយៗមាន៖ មេសា 8-12, 22-26 & 29-30 (១២ ថ្ងៃ); ឧសភា 2-3, 6-9, 20-23, 27 & 29-31 (១៤ ថ្ងៃ); មិថុនា 4-7, 10-13, 17, 19-21 & 24-27 (១៦ ថ្ងៃ); កក្កដា 1-4, 8-11, 15-18, 22-25 & 29-31 (១៩ ថ្ងៃ)។ សវនាការសម្រាប់ថ្ងៃសុក្រមួយចំនួនតូច ត្រូវបានស្នើឡើង ជាបឋមគឺដើម្បីបំពេញឲ្យថ្ងៃដែលបាត់បង់ដែលបណ្តាលមកពីចំលើថ្ងៃឈប់សម្រាកជាសាធារណៈ ឬនៅជុំវិញសប្តាហ៍ទាំងនោះ។

ជនជាប់ចោទ) ឧក្រិដ្ឋកម្មនៃការជម្លៀសដោយបង្ខំ និងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ។ ការលៃលកពេលវេលាសរុបដែលបានស្នើឡើងសម្រាប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណីឬអ្នកជំនាញម្នាក់ៗ បង្ហាញឲ្យឃើញតាមរយៈអក្សរដិតធំ ជាប់ពីមុខឈ្មោះបុគ្គលម្នាក់ៗទាំងនេះ។ តាមការពន្យារពេលដែលធ្លាប់បានជួបប្រទះតាំងពីចាប់ផ្តើមដំបូងនៃឆ្នាំនេះ សហព្រះរាជអាជ្ញាបានស្នើឲ្យមានការកាត់បន្ថយពេលវេលាសរុបនៃពេលវេលាដែលបានលៃទុក សម្រាប់សាក្សីមួយចំនួន[4] និងស្នើឲ្យអង្គជំនុំជម្រះពន្យារផែនការរបស់ខ្លួន ដើម្បីស្តាប់សក្ខីកម្មពីសាក្សីជំនាញ TCE-80[5]។

៤- បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់រួចរាល់នូវសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញចំនួន១២នាក់ សូមស្នើឲ្យបែងចែករយៈពេលចំនួន៨ថ្ងៃ សម្រាប់ស្តាប់ចម្លើយសាក្សីបន្ថែមដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ចាត់ទុកថាជាការចាំបាច់ដើម្បីដាក់បន្ទុកក្នុងការបង្ហាញភ័ស្តុតាងស្តីពីបញ្ហានានាដូចជា តួនាទីរបស់ជនជាប់ចោទ, អត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួម(ដែលជាប់ទាក់ទងទៅនឹងការជម្លៀសចេញដោយបង្ខំ, និងការផ្តោតមុខសញ្ញាទៅរកប្រជាជនដែលជាប់ពាក់ព័ន្ធនឹងរបបលន់ ណល់ និងការអប់រំកែប្រែឡើងវិញ ឬការកម្ទេចខ្មាំង) និងការប្រព្រឹត្តិឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់។ បន្ទាប់ពី៨ថ្ងៃដែលបានបែងចែកទៅឲ្យសហព្រះរាជអាជ្ញា សូមស្នើឲ្យបែងចែកចំនួន១២ថ្ងៃសម្រាប់ការស្តាប់ពីអង្គហេតុ និងសាក្សីផ្តល់សក្ខីកម្មអំពីអត្តចរិត ដែលបានស្នើឡើងដោយមេធាវីការពារក្តី និងបួនថ្ងៃបន្ទាប់មកទៀត បែងចែកសម្រាប់ការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីផលប៉ះពាល់ផ្សេងៗចំពោះជនរងគ្រោះ។

៥- សហព្រះរាជអាជ្ញាបានបញ្ជាក់នៅក្នុង**ឧបសម្ព័ន្ធ** ក អំពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំឲ្យធ្វើការស្តាប់ចម្លើយនៅក្នុងអម្លុងពេលប្រាំបីថ្ងៃ។ សាក្សីទាំងអស់ត្រូវបានសហព្រះរាជអាជ្ញាស្នើឡើងនៅក្នុងបញ្ជីដើមនៃសាក្សីរបស់ខ្លួនដោយអនុលោមតាមវិធាន៨០នៃវិធានផ្ទៃក្នុង កាលពីក្នុងខែមករា ឆ្នាំ២០១១[6] ដោយលើកលែងតែសាក្សីថ្មីម្នាក់ចេញ ដែលត្រូវបានដាក់តាមសំណើសុំឲ្យធ្វើការ

[4] និយាយឲ្យចំ គឺស្នើថា ពេលវេលាសម្រាប់សវនាការស្តាប់សាក្សី TCW-110 ត្រូវកាត់បន្ថយពីចំនួន២ថ្ងៃ មកត្រឹម១ថ្ងៃ សាក្សី TCW-536 បន្ថយពី ២ថ្ងៃកន្លះ មកត្រឹម២ថ្ងៃ ហើយអ្នកជំនាញ TCE-33 និង TCE-65 ពី៤ថ្ងៃ មកត្រឹម៣ថ្ងៃ។

[5] ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាស្នើថា អាចស្តាប់សវនាការលោកស្រី Becker តែក្នុងករណីដែលអង្គជំនុំជម្រះមិនអាចកំណត់ពេលការមកផ្តល់សក្ខីកម្មរបស់សាក្សី TCE-33 ឬ TCE-65 ប៉ុណ្ណោះ (ដោយផ្ទាល់ ឬតាមរយៈវីឌីអូលីង)។ មូលហេតុសម្រាប់ការផ្តល់អាទិភាពចំពោះសាក្សី TCE-33 និង TCE-65 គឺដោយសារអ្នកជំនាញទាំងពីររូបនេះ ក៏ត្រូវបានស្នើឡើង និងចាត់ទុកថាមានសារសំខាន់ ដោយក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន រៀងៗខ្លួន។

[6] ឯកសារលេខ **E9/4.1** ឧបសម្ព័ន្ធទី១ដែលភ្ជាប់មកជាមួយនឹងបញ្ជីអ្នកជំនាញ សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៨ មករា ២០១១។

សើុបសួរនាពេលថ្មីៗនេះ[7]។ សាក្សីជាច្រើននៅក្នុងចំណោមសាក្សីទាំងនេះ ត្រូវបានស្នើសុំឱ្យស្តាប់ចម្លើយក្នុងរយៈពេលកន្លះថ្ងៃ ដែលក្នុងនោះសហព្រះរាជអាជ្ញានឹងពឹងផ្អែកជាសំខាន់ទៅលើចម្លើយសាក្សីដែលមានស្រាប់ ហើយគ្រាន់តែបើកធ្វើការសួរដេញដោលខ្លីមួយ ដោយផ្តោតទៅលើព័ត៌មានជាចំបងដែលបានផ្តល់ដោយសាក្សី ដោយទុកពេលគ្រប់គ្រាន់សម្រាប់ការសួរដេញដោលដោយមេធាវីការពារក្តី។

៦- សាក្សីភាគច្រើនដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ត្រូវបានធ្វើការជ្រើសរើស ពីព្រោះសាក្សីបានផ្តល់ព័ត៌មានដែលជាប់ទាក់ទងអំពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ។ អនុលោមតាមការសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ផ្នែកទាំងនេះនៃចម្លើយរបស់សាក្សីមិនអាចទទួលយកបានទេ លុះត្រាតែសាក្សីទាំងនេះត្រូវបានកោះហៅ និងអាចមានលទ្ធភាពឱ្យធ្វើការសួរដេញដោលបាន[8]។ សេចក្តីសង្ខេបមួយអំពីមូលហេតុសម្រាប់ការកោះហៅសាក្សីម្នាក់ៗ ក្នុងចំណោមសាក្សីទាំងនេះដែលបានស្នើឡើង គឺដូចមានចែងខាងក្រោមនេះ៖

ក- សាក្សីដើមបណ្តឹងរដ្ឋប្បវេណី TCCP-186 ផ្តល់សក្ខីកម្មលម្អិតអំពីការអប់រំនយោបាយដែល ខៀវ សំផន និង នួន ជា បានបង្រៀនដល់កម្មាភិបាល បកក ស្តីពីបញ្ហាដូចជា ជ័យជំនះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ការចាប់ខ្លួន និងការសម្លាប់ខ្មាំងផ្ទៃក្នុង (រួមមាន ទាហាន លន់ ណល់ នគរបាល រដ្ឋការស៊ីវិល)[9]។

ខ- សាក្សី TCW-505 គឺជាលេខាស្រុកត្រាំកក់ ក្នុងអំឡុងរយៈពេលដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សាក្សីនេះបានចូលរួមវគ្គសិក្សានយោបាយប្រចាំឆ្នាំដែលដឹកនាំដោយ នួន ជា សម្រាប់លេខាទាំងអស់មកពីទូទាំងប្រទេស ដែលនៅទីនោះសិក្ខាកាមទាំងអស់ បានទទួលការណែនាំ ពី នួន ជា ឱ្យ "ត្រួតពិនិត្យមើលប្រជាជន"។ សាក្សីក៏បានបញ្ជាក់ផងដែរអំពីការបំបែក និងការបាត់ខ្លួនរបស់ទាហាន លន់ ណល់ ឱ្យដាច់ពីអ្នកជម្លៀស១៧ មេសា ដែលបានជម្លៀសទៅស្រុកត្រាំកក់[10]។

---

[7] **E266** សំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩៣ សុំបើកកិច្ចស៊ើបសួរអំពីទីកន្លែងរបស់សាក្សីសក្តានុពល, ១៩ កុម្ភៈ ២០១៣។

[8] **E96/7** សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ទាក់ទងនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងភស្តុតាងដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ២០ មិថុនា ២០១២, កថាខណ្ឌទី២១-២២។។

[9] **D230/1.1.874c** បទសម្ភាសន៍របស់ DC-Cam, ៥-៦ ឧសភា ២០០៩, ទំព័រទី៣៩-៤០, ៥៥-៦៦។

[10] **E3/401** កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស, ទំព័រទី៦។ **D232/16** កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស, ទំព័រទី៧-៨។

គ- សាក្សី TCW-164 រៀបរាប់អំពីវគ្គបំពាក់បំប៉នផ្នែកនយោបាយ នៅបូរីកីឡា ដែល ខៀវ សំផន បានពិភាក្សាអំពីការចាប់ខ្លួន ប៉ង់ ពីមន្ទីរ ៨៧០ ដោយសារ "គាត់ជាជនក្បត់ចូលដៃជាមួយយួន" និង នួន ជា បានរៀបរាប់ពីអំពើក្បត់របស់ កុយ ធួន និងក្រុមភូមិភាគឧត្តររបស់គាត់[11]។

ឃ- សាក្សី TCW-781 គឺជាកម្មករនៅក្រសួងពាណិជ្ជកម្ម រៀបរាប់អំពីការចាប់ខ្លួន និងការបាត់ខ្លួនរបស់កម្មករដែលគេហៅ "ឲ្យទៅរៀនសូត្រ" ការត្រួតពិនិត្យឃ្លាំងរបស់ក្រសួង ដោយ ខៀវ សំផន, វ៉ាន់ រិទ្ធិ និង នួន ជា និងការជួបប្រជុំមួយ ដែលបានធ្វើឡើងនៅដើមខែមករា ឆ្នាំ១៩៧៩ ដែលអ្នកទាំងបីបានប្រកាសឲ្យ "បញ្ឈប់ការហៅទៅរៀនសូត្រ" ពីព្រោះតែភាពចាំបាច់ឲ្យមាន "ការបង្រួបបង្រួមដើម្បីវាយខ្មាំង"[12]។

ង- សាក្សីថ្មីដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា (សាក្សីនៃកម្មវត្ថុនៃសំណើសុំបំពេញកិច្ចស៊ើបសួរដែលកំពុងរង់ចាំការសម្រេច ដូច្នេះហើយអត្តសញ្ញាណរបស់គាត់ត្រូវបានរក្សាការសម្ងាត់) រៀបរាប់អំពីការពិភាក្សារបស់មេដឹកនាំបកក នៅមុនឆ្នាំ១៩៧៥ ទាក់ទងនឹងការជម្លៀសដោយបង្ខំ និងបញ្ជាក់ថា ខៀវ សំផន គាំទ្រការជម្លៀសទីក្រុងភ្នំពេញ[13]។

ច- សាក្សី TCW-720 បានដឹកនាំការធ្វើសម្ភាសន៍ជាច្រើនជាមួយ នួន ជា ដែលបទសម្ភាសន៍ទាំងនោះ ត្រូវបានប្រើប្រាស់ជាភាពយន្តឯកសារ និងបានបោះពុម្ពផ្សាយជាសៀវភៅមួយក្បាលពឹងផ្អែកលើសៀវភៅសរសេរដៃដែលផ្តល់ជូនគាត់ដោយ នួន ជា[14]។ សៀវភៅនោះមានកំណត់ហេតុលម្អិតទាក់ទងនឹងតួនាទីរបស់ នួន ជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងក្បាលម៉ាស៊ីនសន្តិសុខ និងដំណើការជាសមោហភាពធ្វើឡើងដោយមេដឹកនាំ បកក ក្នុងការសម្រេចលើគោលនយោបាយនិងបញ្ហាផ្សេងៗ។ វាជារឿងរ៉ាវដ៏ទូលំទូលាយពីមេដឹកនាំជាន់ខ្ពស់ម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ។

ឆ- សាក្សី TCW-725 ផ្តល់នូវសក្ខីកម្មដ៏សំខាន់អំពីសហកម្មឧក្រិដ្ឋកម្មរួម (JCE) ដែលក្នុងនោះថ្នាក់ដឹកនាំក្រសួង និងមេដឹកនាំ បកក បានចូលរួមជាសមូហភាព ក្នុងការចាប់ខ្លួន

[11] **E3/474** (D94/8) កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស, ទំព័រទី៤-៥។

[12] **E3/437** (D279/3) កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស។

[13] **D313/1.2.405** បទសម្ភាសន៍របស់ Ben Kiernan, ២៦ សីហា ១៩៨១, ទំព័រទី១។

[14] **E1/22.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ១៤ ធ្នូ ២០១១ ត្រង់ទំព័រទី៤៤-៤៥, ៥០-៥១។ **E152.2** ។

និងការបោសសម្អាតអង្គការនានារបស់កម្ពុជាប្រជាធិបតេយ្យ។ សាក្សីធ្លាប់បានជួប និង ធ្លាប់បានស្នើសុំ ខៀវ សំផន ដោយផ្ទាល់នូវការផ្គត់ផ្គង់ខាងផ្នែកពេទ្យ មានការបញ្ជាក់អះអាងអំពីការទទួលខុសត្រូវរបស់គាត់ខាងកិច្ចការពាណិជ្ជកម្ម និងរៀបរាប់អំពីការចុះមកពិនិត្យនៅក្រសួងសង្គមកិច្ច ដោយ នួន ជា[15]។

ជ- សាក្សី TCW-354 ជាអតីតកម្មាភិបាល ក-១ ថ្លែងថា ប៉ុល ពត, នួន ជា និង ខៀវ សំផន តែងតែនៅជាមួយគ្នានៅ ក-១ និងថា ខៀវ សំផន នៅពីលើ ប៉ង់[16] ដែលសក្ខីកម្មនោះបង្ហាញពីតួនាទី ខៀវ សំផន នៅមន្ទីរនយោបាយ ៨៧០។

ឈ- សាក្សី TCW-648 និង TCW-696 គឺជាកម្មាភិបាលនៃក្រសួងពាណិជ្ជកម្ម រៀបរាប់អំពីរចនាសម្ព័ន្ធរបស់ក្រសួងនេះ ការបោសសម្អាតកម្មាភិបាលរបស់ក្រសួងនេះ និងការចុះមកត្រួតពិនិត្យឃ្លាំងរបស់ក្រសួងនេះដោយ ខៀវ សំផន នៅទួលទំពូង។ សាក្សី TCW-648 ក៏ធ្លាប់បានចូលរួមប្រជុំមួយដែលដឹកនាំដោយ ខៀវ សំផន ផងដែរនៅដើមខែមករា ឆ្នាំ ១៩៧៩ ដែលនៅក្នុងកិច្ចប្រជុំនេះ គាត់បានបញ្ជាឲ្យកម្មាភិបាលត្រៀមការពារប្រឆាំងនឹងវៀតណាម[17]។ (មកទល់ពេលនេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ភស្តុតាងនៃសាក្សីតែម្នាក់ប៉ុណ្ណោះមកពីក្រសួងពាណិជ្ជកម្ម- គឹម លុត )។ ពីព្រោះក្រសួងនេះមកពីក្រសួងដែលស្ថិតនៅក្រោមសិទ្ធិអំណាចនិងការត្រួតត្រារបស់ ខៀវសំផន គួរបានធ្វើការស្តាប់សាក្សីលើសពីនេះទៀត ដែលស្របតាមវិធីសាស្ត្ររបស់អង្គជំនុំជម្រះចំពោះក្រសួងការបរទេស)។

ញ- សាក្សី TCW-79 គឺជាកម្មាភិបាលនៃកងពលធំ ៥០២ ដែលត្រូវបានចាត់តាំងឲ្យគ្រប់គ្រងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង និយាយថា ខៀវ សំផន បានចុះមកពិនិត្យមើលទីតាំងលុតដុំយោធា និងបានជួបថ្នាក់ដឹកនាំនៃការដ្ឋាននេះ[18]។ ហេតុនេះ សក្ខីកម្មរបស់គាត់បង្ហាញឲ្យឃើញអំពីតួនាទីរបស់ ខៀវ សំផន ថាជាមេដឹកនាំជាន់ខ្ពស់មួយរូបដែលបានដឹង

---

[15] **D199/18** កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់, ៥ មិថុនា ២០០៩, ទំព័រទី៣។ **E3/378** កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់, ទំព័រទី២-៤។

[16] **D224.17** បទសម្ភាសន៍របស់ SOAS, ២៧ កក្កដា ២០០៥។

[17] **E3/472** កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស, ទំព័រទី៣-៤។ **IS 19.177** បទសម្ភាសន៍របស់ DC-Cam, ១៣ កុម្ភៈ ២០០៣, ទំព័រទី៣៧-៣៨។ **IS 19.192** បទសម្ភាសន៍របស់ DC-Cam, ២ កុម្ភៈ ២០០៣, ទំព័រទី៣៨។

[18] **D166/116** កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស, ទំព័រទី៦។

អំពីទីតាំងយោធា និងការចូលរួមទីតាំងយោធាដែលគេបានប្រើសម្រាប់លត់ដំ ចំពោះពួកយោធា។

ង- សាក្សី TCW-386 និង TCW-651 គឺជាយោធាស្រុក រៀបរាប់ពីរបៀបដែលបន្ទាប់ពីមានការជួបប្រជុំនានា និងមានបញ្ជាពីមន្ត្រី បកក ទាហាន មន្ត្រីរាជការ និងមូលធននៃរបបលន់ នល់ ត្រូវបានគេកំណត់អត្តសញ្ញាណនៅក្នុងចំណោមជនជម្លៀសថ្មី១៧មេសា និងការយកទៅសម្លាប់ចោល។ អ្នកទាំងពីរមានវត្តមាននៅទីតាំងនោះនៅពេលដែលការសម្លាប់បានកើតឡើង[19]។ ស្រុករបស់ពួកគាត់ គឺជាមូលដ្ឋានគន្លឹះរបស់ បកក ដែល ប៉ុល ពត, នួន ជា និង ខៀវ សំផន បានបោះទីតាំងនៅទីនេះជាច្រើនខែរហូតដល់ដល់ថ្ងៃទី១៧ មេសា ១៩៧៥ និងជាទីកន្លែងដែលក្រោយមកត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការមជ្ឈិម បកក ថាជា "ស្រុកគំរូ" មួយក្នុងចំណោមស្រុកគំរូទាំងបីនៅក្នុងប្រទេស[20]។

៧- ចំណែកឯរយៈពេលចំនួន១២ថ្ងៃដែលបានស្នើសម្រាប់ការស្តាប់សាក្សីអង្គហេតុ និងសាក្សីអត្តចរិតរបស់មេធាវីការពារក្តី សហព្រះរាជអាជ្ញាយល់ឃើញថា គឺជាការចាំបាច់ មុនការបញ្ចប់សវនាការដែលជនជាប់ចោទគួរតែត្រូវបានផ្តល់ឱកាសឲ្យក្នុងការកោះហៅសាក្សីខាងអង្គហេតុ និងខាងអត្តចរិតដែលមេធាវីការពារក្តីបានកំណត់ថា ជាការចាំបាច់សម្រាប់ការការពារក្តីរបស់ខ្លួន។ កន្លងមក អង្គជំនុំជម្រះសាលាដំបូងបានបែងចែកពេលវេលាសរុបទាំងអស់ចំនួនបីថ្ងៃ ទៅឲ្យក្រុមមេធាវីការពារក្តីនីមួយៗ ដើម្បីស្តាប់សក្ខីកម្មសាក្សីអំពីអត្តចរិត។ សហព្រះរាជអាជ្ញាស្នើថា ចំនួនថ្ងៃនេះត្រូវបានបន្ថែមឲ្យបានចំនួន៦ថ្ងៃសម្រាប់ក្រុមមេធាវីនីមួយៗ ហើយថាមេធាវីការពារក្តីគួរត្រូវបានអនុញ្ញាតឲ្យស្នើសាក្សីអត្តចរិត ឬសាក្សីអង្គហេតុ។ សាក្សីដែលបានស្នើដោយជនជាប់ចោទ (និងសហព្រះរាជអាជ្ញា) ពិតណាស់ អាចទទួលបានការអនុញ្ញាតពីអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន៨៧ នៃវិធានផ្ទៃក្នុង។

៨- ពេលវេលាចំនួន១២ថ្ងៃ សម្រាប់មេធាវីការពារក្តី នៅក្នុង**ឧបសម្ព័ន្ធ** ក រួមមាន សាក្សីអង្គហេតុចំនួន ០២នាក់ ដែលស្នើដោយមេធាវីការពារក្តី ត្រូវបានអង្គជំនុំជម្រះសាលាដំបូង ទទួលយករួចហើយ (TCW-570 និង TCW-126)។ សាក្សីពីរនាក់ផ្សេងទៀតដែលមេធាវីការពារក្តី នួន ជា បានស្នើសុំ

[19] **D125/68** កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស, ទំព័រទី៥-៧។ **D125/91** កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស, ទំព័រទី៥។

[20] **E3/135** ទង់បដិវត្ត, ចេញផ្សាយ ៦ មិថុនា ១៩៧៧, ត្រង់ ERN 00446848-52។

ត្រូវបានអង្គជំនុំជម្រះអនុម័តរួចហើយកាលពីមុន ថាជាសាក្សីបម្រុង (TCW-258 និង TCW-643) ហើយសហព្រះរាជអាជ្ញាបានយល់ស្របតាមសំណើរបស់មេធាវីការពារក្តី ក្នុងការកោះហៅសាក្សី TCW-230 ឬសាក្សី TCW-539 ថាជាការសមស្រប។ សហព្រះរាជអាជ្ញាមិនជឿថា មេធាវីការពារក្តី មានហេតុផលស្របច្បាប់ក្នុងការកោះហៅសាក្សីដែលខ្លួនបានស្នើសុំ ផ្តល់សក្ខីកម្មអំពីការទម្លាក់គ្រាប់បែករបស់អាមេរិកមុនឆ្នាំ១៩៧៥ (ដូចជា សាក្សី TCW-342 និងសាក្សី TCW-62 និងសាក្សី TCW-628) ពីព្រោះថាមានសាក្សីជាច្រើនបានផ្តល់សក្ខីកម្មរួចហើយចំពោះអង្គហេតុនេះ។ ការទម្លាក់គ្រាប់បែកបែបនេះគ្មានភាគីណាមួយជំទាស់ដែរ ហើយប្រធានបទនេះអាចដោះស្រាយបន្ថែមទៀតបាន (ក្នុងករណីចាំបាច់) តាមរយៈសាក្សីជំនាញដែលសង្ឃឹមថានឹងមកបន្តបន្ទាប់នេះ។ មេធាវីការពារក្តី ខៀវ សំផន បានស្នើសាក្សីអត្តចរិត និងអង្គហេតុ ហើយសហព្រះរាជអាជ្ញាពីមុនបានបញ្ជាក់ថា សហព្រះរាជអាជ្ញាមិនជំទាស់នឹងសាក្សីទាំងនោះដែរ។

៩- ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីសវនាការដេញដោលលើភស្តុតាងដែលស្នើ នៅក្នុង**ឧបសម្ព័ន្ធ ក** នឹងបញ្ចប់ទៅដោយការស្តាប់ចម្លើយសាក្សី ស-២១ (អាស្រ័យលើអង្គជំនុំជម្រះសាលាដំបូង ដាក់បញ្ចូលទីកន្លែងឧក្រិដ្ឋកម្មនេះ នៅក្នុងវិសាលភាពនៃសវនាការបន្ទាប់ពីមានដីកាបំបែកកិច្ចដំណើរការនីតិវិធី) និងការបញ្ចប់សវនាការដេញដោលលើឯកសារសំខាន់ៗដែលនៅសេសសល់។ កាលវិភាគដែលបានស្នើសម្រាប់ ស-២១ រួមមាន សាក្សីចំនួន០៥នាក់ ដែលសហព្រះរាជអាជ្ញាបានស្នើពីលើកមុន (ដែលសាក្សីទាំងអស់នោះ ក៏បានស្នើសុំដោយមេធាវីការពារក្តី នួន ជា ផងដែរ) និងការកំណត់រយៈពេលចំនួន០៤ថ្ងៃ ទុកសម្រាប់សាក្សីក្រោយៗ ដែលមេធាវីការពារក្តី ឬដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំ ហើយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាចាំបាច់។

១០- ទាក់ទងទៅនឹងអត្តិភាពជម្លោះប្រដាប់អាវុធ សហព្រះរាជអាជ្ញាមិនជឿថាមានភាពចាំបាច់ដើម្បីកោះហៅសាក្សី TCE-10 ឬសាក្សីណាមួយផ្សេងទៀតឲ្យលើសពីសាក្សីដែលបានដាក់ផែនការរួចហើយដែរ។ បន្ទាប់ពីមានមតិណែនាំពីអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ ក្នុងសវនាការ សហព្រះរាជអាជ្ញាបានពិនិត្យឡើងវិញពីកំណត់ហេតុក្នុងសំណុំរឿង០០១ និងកត់សម្គាល់ថា សាក្សី TCE-10 គឺជាសាក្សីម្នាក់គត់ដែលត្រូវបានកោះហៅដោយអង្គជំនុំជម្រះ ផ្តល់សក្ខីកម្មអំពីអត្តិភាពជម្លោះប្រដាប់អាវុធ និងថាសក្ខីកម្មរបស់គាត់ត្រូវបញ្ចប់មិនលើសពីមួយថ្ងៃកន្លះ[21]។

[21] **D288/4.24.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ (សំណុំរឿង ០០១), ២៥ ឧសភា ២០០៩។ **D288/4.25.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ (សំណុំរឿង ០០១), ២៦ ឧសភា ២០០៩។

ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ" គឺជាប្រធានបទមួយក្នុងចំណោមប្រធានបទជាច្រើនដែលសក្ខីកម្មរបស់សាក្សីម្នាក់ៗ អាចត្រូវបានទទួលយក និងចាត់ទុកថាគ្មានការចូលរួមរបស់សាក្សីនៅពេលសវនាការ[22]។ ប្រសិនបើសាក្សី TCE-10 មិនត្រូវបានកោះហៅ នោះអង្គជំនុំជម្រះសាលាដំបូងនឹងត្រូវស្តាប់សាក្សីច្រើនទៀតដែលផ្តល់សក្ខីកម្មអំពីជម្លោះប្រដាប់អាវុធក្នុងសវនាការ ជាជាងស្តាប់សក្ខីកម្មនៅសវនាការក្នុងសំណុំរឿង០០១ ដោយរួមមាន សាក្សី TCW-398 (នឹងរៀបរាប់អំពីការរាយការណ៍របស់ សុន សេន ទៅមេដឹកនាំនៅភ្នំពេញស្តីពីជម្លោះប្រដាប់អាវុធជាមួយវៀតណាម) សាក្សី TCW-110 និងសាក្សី TCW-253 (ជាមេបញ្ជាការយោធាភូមិភាគនិរតីត្រូវបានចាត់តាំងឲ្យទៅឈរជួរក្នុងសមរភូមិមុខប្រឆាំងនឹងវៀតណាម) ហើយមានសាក្សីមួយចំនួនទៀតបានផ្តល់សក្ខីកម្មរួចហើយ (ឧទាហរណ៍ សាក្សី សៅ សារុន និងជនជាប់ចោទ នួន ជា ខ្លួនគាត់ផ្ទាល់) ដែលបានយោងជាញឹកញាប់ពីជម្លោះជាមួយវៀតណាម។ នៅទីបញ្ចប់ សហព្រះរាជអាជ្ញាបានកត់សំគាល់ឃើញថា មិនដូចជា សំណុំរឿងលេខ០០១ ដែល ឌុច មិនបានទទួលនូវឯកសារនានានៅក្នុងសហសម័យ ដែលលើកឡើងពិភាក្សាអំពីជម្លោះប្រដាប់អាវុធនោះទេ នៅក្នុងករណីនេះការដឹងឮរបស់ជនជាប់ចោទអំពីជម្លោះប្រដាប់អាវុធ គឺត្រូវបានបង្ហាញភ័ស្តុតាងដោយផ្ទាល់តាមរយៈរបាយការណ៍នានាដែលពួកគេបានទទួល, កំណត់ហេតុប្រជុំដែលពួកគេបានចូលរួម, និងសន្ទរកថា ឬ របាយការណ៍នានា ដែលពួកគេបានធ្វើ។ ហេតុដូចនេះ បញ្ហានានាដែលទាក់ទងនិងជម្លោះប្រដាប់អាវុធអាចត្រូវបានលើក ឡើងយ៉ាងឆាប់រហ័សនៅក្នុងសវនាការ ដោយពុំមានការផ្លាស់ប្តូរ ឬពន្យារពេលនៃកាលវិភាគ សវនាការដូចដែលបានស្នើឡើងបច្ចុប្បន្ននេះនោះទេ។

១១- ទាក់ទងទៅនឹងសវនាការដេញដោលលើឯកសារ កាលវិភាគសវនាការដែលសហព្រះរាជអាជ្ញាបានស្នើ មានរួមបញ្ចូល ០១(មួយ)ថ្ងៃ ទុកសម្រាប់ការបង្ហាញឯកសារទាក់ទងនឹងតួនាទីរបស់ នួន ជា និងរយៈពេលសរុបចំនួន៤)ថ្ងៃ នៅចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធីទុកសម្រាប់សវនាការទាក់ទងនឹងភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី, ឯកសារ ស-២១ បន្ថែមទៀតដែលអង្គជំនុំជម្រះសាលាដំបូងនៅមិនទាន់បានទទួលយកនៅឡើយ នៅមុនពេលមានសេចក្តីសម្រេចនានា និងទុកសម្រាប់ធ្វើការដោះស្រាយលើការជំទាស់ ទៅនឹងឯកសារណាមួយក៏ដោយ ដែលមេធាវីការពារក្តីបានចោទប្រកាន់ថាគេមិនទាន់បានបកប្រែនៅឡើយ។ (សវនាការដេញដោលលើឯកសារដែលបានស្នើ

[22] ឯកសារលេខ **E96/7** សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារផ្សេងៗទៀត នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន៩២ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២០ មិថុនា ២០១២, កថាខណ្ឌទី២៩(ខ)។

នៅក្នុង **ឧបសម្ព័ន្ធ** ក ត្រូវបានដាក់ជា អក្សរពណ៌ស្វាយ ដើម្បីងាយស្រួលធ្វើការយោងសេចក្តី)។ សហព្រះរាជអាជ្ញាមិនបានដាក់បញ្ចូលនៅក្នុង **ឧបសម្ព័ន្ធ** ក ការបង្ហាញជូននូវឯកសារដែលទាក់ទងនឹងគោលនយោបាយនៃសហកម្មឧក្រិដ្ឋកម្មរួមទេ ក៏ប៉ុន្តែជឿថាការបង្ហាញជូននូវឯកសារបែបនេះគួរតែបានបន្តធ្វើក្នុងករណីដែលចំនួនថ្ងៃសវនាការរបស់តុលាការអាចមានលទ្ធភាពឲ្យធ្វើទៅបានដោយហេតុមកពីជនជាប់ចោទមានជម្ងឺឬសាក្សីមួយចំនួនមិនអាចមកបាន ហើយនឹងត្រៀមលក្ខណៈដើម្បីបន្តដំណើរការតទៅទៀតក្នុងការបង្ហាញជូននូវឯកសារទាំងនេះ ដោយធ្វើការជូនដំណឹងក្នុងរយៈពេលដ៏ខ្លី។

១២- កាលវិភាគដែលបានស្នើឡើងនេះ អនុញ្ញាតឲ្យមានការសម្រាកមួយរយៈពេល នៅដើមខែសីហា ឆ្នាំ២០១៣។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ភាគីនានាត្រូវដាក់សេចក្តីសន្និដ្ឋានបិទការពិភាក្សាដេញដោលក្នុងរយៈពេលចំនួន០៦សប្តាហ៍ បន្ទាប់ពីការបញ្ចប់កិច្ចដំណើរការនីតិវិធីដេញដោលលើភ័ស្តុតាង (គឺថា នៅពាក់កណ្តាលខែកញ្ញា ឆ្នាំ២០១៣) ដំបូងតែមួយភាសា ប្រសិនបើការបកប្រែភាសាមិនអាចបកប្រែចប់នៅពេលនោះ ហើយសេចក្តីសន្និដ្ឋានបិទការពិភាក្សាដេញដោល គួរបានកំណត់កាលវិភាគនៅចុងខែកញ្ញា ឆ្នាំ២០១៣៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |